# សុន្ទរកថា
# អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
# ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# ថ្លែងក្នុង
# ពិធីអបអរសាទរខួប ២៥ ឆ្នាំ
# នៃការបង្កើតធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម (ARDB)

សណ្ឋាគារ ហ្គាឌិន ស៊ីធី (Garden City Hotel)

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០២៣

- ឯកឧត្តមបណ្ឌិត **សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់;
- ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និង ជាប្រធានក្រុមប្រឹក្សាស្ដារ អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ;
- ឯកឧត្តម **ហ្លួត ហាក់** រដ្ឋមន្ត្រី ក្រសួងអធិការកិច្ច;
- លោកជំទាវ **សោម គឹមសួគ៌** អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ;
- លោកជំទាវ **អ៊ុក ម៉ាលី** ទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា;
- ឯកឧត្តមបណ្ឌិត **កៅ ថាច** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក-ធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម;
- ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!

ថ្ងៃនេះ, ខ្ញុំពិតជាមានសេចក្តីសោមនស្សយ៉ាងក្រៃលែង ដោយបានមកចូលរួមជាអធិបតី ក្នុងពិធី «**អបអរសាទរខួប ២៥ ឆ្នាំ នៃការបង្កើតធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម (ARDB)**» ។ ខ្ញុំសូមស្វាគមន៍ ចំពោះ **ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី** ទាំងអស់ ដែលបានឆ្លៀតពេលដ៏មានតម្លៃ អញ្ជើញចូលរួមនៅក្នុងកម្មវិធីដ៏មានសារៈសំខាន់ នាព្រឹកនេះ ។

ខ្ញុំសូមយកឱកាសដ៏ប្រពៃនេះ សម្តែងនូវការអបអរសាទរយ៉ាងកក់ក្តៅ ចំពោះខួប ២៥ ឆ្នាំនៃការបង្កើតធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម ដែលជាធនាគារគោលនយោបាយមួយ ដ៏មានសារៈសំខាន់ ។ ជាមួយគ្នា, ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលជាស្ថាប័នអាណាព្យាបាល របស់ធនាគារនេះ, ខ្ញុំសូមកោតសរសើរ និង វាយតម្លៃខ្ពស់ចំពោះក្រុមប្រឹក្សាភិបាល, ថ្នាក់ដឹកនាំ, មន្ត្រី-បុគ្គលិក គ្រប់ជំនាន់ និង គ្រប់ជាន់ថ្នាក់នៃធនាគារ ដែលបានខិតខំអស់ពីកម្លាំងកាយ-ចិត្ត ក្នុងការបំពេញតួនាទី និង ភារកិច្ចរបស់ខ្លួន ប្រកបដោយវិជ្ជាជីវៈ និង ស្មារតីទទួលខុសត្រូវខ្ពស់ រហូតសម្រេចបាននូវសមិទ្ធផលជាច្រើនគួរឱ្យកត់សម្គាល់ ដូច **ឯកឧត្តម កៅ ថាច ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម** បានគូសបញ្ជាក់មុននេះបន្តិច ។

ផ្សារភ្ជាប់នឹងសមិទ្ធផល ក្នុងរយៈពេល ២៥ ឆ្នាំ ដែល **ឯកឧត្តម កៅ ថាច** ទើបបានគូសរំលេចយ៉ាងក្បោះក្បាយ, ខ្ញុំសូមរំលឹកឡើងវិញបន្តិច អំពីប្រវត្តិ និង បុព្វហេតុនៃការបង្កើត **ធនាគារអភិវឌ្ឍន៍ជនបទ** ។ ជាបរិបទសកល, ក្រោយសង្គ្រាមលោកលើកទី ២ ត្រូវបានបញ្ចប់, ធនាគារអភិវឌ្ឍន៍ជាច្រើន ត្រូវបានបង្កើតឡើង ដោយរដ្ឋាភិបាល ឬ អង្គការមិនមែនរដ្ឋាភិបាលនានា ក្នុងកម្រិតអន្តរជាតិ ជាពហុភាគី, កម្រិតតំបន់ ឬ កម្រិតជាតិ ដើម្បីផ្តល់ហិរញ្ញប្បទាន បម្រើឱ្យការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ ដោយឡែក, នៅកម្ពុជា, ធនាគារអភិវឌ្ឍន៍ជនបទ (RDB) ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៨ និង ត្រូវបានធ្វើបរិវត្តកម្មទៅជាធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម (ARDB) នៅឆ្នាំ ២០១៩, ក្រោមការផ្តួចផ្តើមប្រកបដោយភាពឈ្លាសវៃ និង គតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណា-**

**ចក្រកម្ពុជា**, ក្នុងគោលបំណងផ្តល់ហិរញ្ញប្បទានគាំទ្រដល់វិស័យកសិកម្ម, ដែលជាវិស័យអាទិភាព របស់រាជរដ្ឋាភិបាល, សំដៅលើកស្ទួយកម្រិតជីវភាពរស់នៅ របស់ប្រជាពលរដ្ឋនៅជនបទ និង បំពេញចន្លោះខ្វះខាតនៃការផ្តល់ហិរញ្ញប្បទាន ក្នុងការអភិវឌ្ឍវិស័យកសិកម្ម និង សេដ្ឋកិច្ចជនបទ ។ ខ្ញុំក៏សូមយកឱកាសនេះ រំលឹកដល់ការរួមចំណែក និងគុណូបការៈ មិនអាចកាត់ថ្លៃបាន របស់ **ឯកឧត្តមកិត្តិបវរក្សបណ្ឌិត គាត ឈន់** អតីតឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ដែលបានដឹកនាំក្រុមការងារបច្ចេកទេស, ជាសេនាធិការរបស់រាជរដ្ឋាភិបាល, ក្នុងការសិក្សា រៀបចំបង្កើតធនាគារអភិវឌ្ឍន៍ជនបទនេះឡើង នៅឆ្នាំ ១៩៩៨ និង បានផ្តល់ការគាំទ្រ ក៏ដូចជា ការទំនុកបម្រុងជាបន្តបន្ទាប់ ដល់ធនាគារអភិវឌ្ឍន៍ជនបទ ក្នុងអាណត្តិការងាររបស់ខ្លួន ។ ខ្ញុំក៏សូមអរគុណផងដែរ ដល់ធនាគារជាតិនៃកម្ពុជា, ក្នុងនាមជាស្ថាប័ននិយ័តករនៃវិស័យធនាគារ, ដែលតែងតែផ្តល់ការគាំទ្រឥតងាករេ ដល់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ក្នុងការបំពេញបេសកកម្មរបស់ខ្លួន តាំងពីដើមទីរៀងមកដល់បច្ចុប្បន្ន ។

## **ឯកឧត្តម**, **លោកជំទាវ**, **ឧកញ៉ា**, **លោក**, **លោកស្រី**!

គិតមកទល់ពេលនេះ, គឺមានរយៈពេល ២៥ ឆ្នាំហើយ, ដែលធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម បាន និង កំពុងបន្តកសាងនូវសមិទ្ធផលជាច្រើន ដោយចាប់ផ្តើមពីការបំពេញតួនាទីដំបូងជាធនាគារបោះដុំ ហើយត្រូវបានប្រែក្លាយ ជាធនាគារពាណិជ្ជនៅឆ្នាំ ២០១៩ ដើម្បីបម្រើគោលនយោបាយរបស់រាជរដ្ឋាភិបាល ឱ្យកាន់តែមានប្រសិទ្ធភាព ។ ក្រៅពីសមិទ្ធផលនៃការធ្វើបរិវត្តកម្មគួរជាទីមោទនៈ របស់ធនាគារដែល **ឯកឧត្តម កៅ ថាច** បានគូសរំលេចមុននេះ, ខ្ញុំក៏សូមយកឱកាសដ៏ថ្លៃថ្លានេះជម្រាបជូន **ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី** ទាំងអស់ ជ្រាបបន្ថែម អំពីសមិទ្ធផលសំខាន់ៗ របស់ធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម ក្នុងការចូលរួមអនុវត្តគោលនយោបាយ និង កម្មវិធីពិសេស របស់រាជរដ្ឋាភិបាល ដូចខាងក្រោម ៖

១). បានបង្កើតនូវ **«មូលនិធិទ្រទ្រង់ និង អភិវឌ្ឍន៍វិស័យកសិកម្ម»** ដើម្បីពង្រីកសមត្ថភាពឃ្លាំងស្តុក, ឡសម្ងួត និង ម៉ាស៊ីនកិន និង កែច្នៃស្រូវ-អង្ករ ក្នុងគោលដៅធានាស្ថិរភាពថ្លៃស្រូវ-អង្ករ និង សន្តិសុខស្បៀង, ដែលមានទឹកប្រាក់ប្រមាណ ៣៦ លានដុល្លារអាម៉េរិក;

២). បានផ្តល់ទុនសម្រាប់សាងសង់ឃ្លាំងស្តុក និង ឡសម្ងួតស្រូវ, ដែលមានទឹកប្រាក់ប្រមាណ ៣០ លានដុល្លារអាម៉េរិក, នៅក្នុងខេត្តបាត់ដំបង, កំពង់ធំ, កំពង់ស្ពឺ និង ព្រៃវែង, និង បានផ្តល់ហិរញ្ញប្បទានអន្តរាគមន៍ពិសេស ជាទុនបង្វិល, ដែលមានទឹកប្រាក់ប្រមាណ ៩០ លានដុល្លារអាម៉េរិក, សម្រាប់ប្រមូលទិញស្រូវពីកសិករ ដើម្បីធានាស្ថិរភាព និង រក្សាលំនឹងថ្លៃស្រូវ របស់ប្រជាកសិករ;

៣). បានផ្តល់ហិរញ្ញប្បទានដល់គម្រោងផ្សេងទៀត ពាក់ព័ន្ធនឹងវិស័យកសិកម្ម, ដែលមានទឹកប្រាក់ប្រមាណ ៦៧,៥ លានដុល្លារអាម៉េរិក, ដោយមានកិច្ចសហការ ជាមួយដៃគូអភិវឌ្ឍន៍អន្តរជាតិ ដូចជា ៖ ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD), ធនាគារអភិវឌ្ឍន៍អាស៊ី (ADB), ធនាគារពិភពលោក (World Bank) និង មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD) ក្នុងអត្រាការប្រាក់សម្បទាន ទោះបីជាអត្រាការប្រាក់នៅលើទីផ្សារអន្តរជាតិ និង អត្រាការប្រាក់ក្នុងស្រុក បានកើនឡើងយ៉ាងណាក្តី; និង

៤). បានអនុវត្តកញ្ចប់វិធានការអន្តរាគមន៍ពិសេស ក្នុង «**ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ច ក្នុងការរស់នៅជាមួយជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ឆ្នាំ ២០២១-២០២៣**», ដែលមានទឹកប្រាក់ប្រមាណ ១៧៨ លានដុល្លារអាម៉េរិក ។

លើមូលដ្ឋាននៃសមិទ្ធផលដែលសម្រេចបាន ក្នុងរយៈពេល ២៥ ឆ្នាំ កន្លងទៅ, ធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម នឹងបន្តបំពេញតួនាទីដ៏សំខាន់ ក្នុងការចូលរួមអនុវត្ត **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាល ទី ១**, **ជាពិសេស មុំទី ៣ នៃបញ្ចកោណទី ៤**, **ពោលគឺ ការលើកស្ទួយកសិកម្ម និង ការអភិវឌ្ឍជនបទ**, ដែលត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា, ក្រោមការដឹកនាំដ៏ប៉ិនប្រសប់, ស្វាហាប់ និង ឈ្លាសវៃ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលជាអគ្គមគ្គុទេសក៍វ័យក្មេងដ៏ឆ្នើម, ពោរពេញដោយសមត្ថភាព, ចំណេះដឹង និង ថាមពល ។ ជាក់ស្តែង, រាជរដ្ឋាភិបាល បានសម្រេចប្រគល់ជូនធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម នូវតួនាទីគន្លឹះ ក្នុងការអនុវត្ត **កម្មវិធី**

**គោលនយោបាយ អាទិភាព ទី ៥** របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា នៅក្នុង «**យន្តការសម្របសម្រួល និង កម្មវិធីហិរញ្ញប្បទាន សំដៅលើកស្ទួយផលិតកម្ម, ស្វែងរកទីផ្សារ និង រក្សាលំនឹងថ្លៃកសិផលសំខាន់ៗ ក្នុងកម្រិតសមរម្យ**», ក្នុងករណីមានវិបត្តិនៃថ្លៃកសិផល, ដែលមានទឹកប្រាក់ប្រមាណ ១០០ លានដុល្លារអាម៉េរិក ។

ជាការពិត, ការលើកស្ទួយវិស័យកសិកម្ម និង ការអភិវឌ្ឍជនបទ នៅតែជាអាទិភាពចម្បងមួយ របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា ។ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាល ទី ១** បានដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រ នៃការ-បន្តពង្រឹងតួនាទី និង អភិវឌ្ឍវិស័យកសិកម្មកម្ពុជា ឱ្យកាន់តែមានលក្ខណៈទំនើប និងមានភាពធន់កាន់តែខ្ពស់ ព្រមទាំងការបន្តគាំទ្រដល់ការអភិវឌ្ឍជនបទ សំដៅធានាសន្តិសុខ និង សុវត្ថិភាពស្បៀង, បង្កើនតម្លៃបន្ថែមកាន់តែខ្ពស់, ជំរុញភាពប្រកួតប្រជែង និង លើកកម្ពស់គុណភាព និង កម្រិតជីវភាពរស់នៅ របស់ប្រជាពលរដ្ឋនៅជនបទ ក៏ដូចជាកាត់បន្ថយគម្លាត រវាងអ្នករស់នៅទីក្រុង និង អ្នករស់នៅជនបទ ។

## ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!

ក្នុងស្មារតីជំរុញប្រសិទ្ធភាពប្រតិបត្តិការ របស់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ក្នុងការចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ដូចបានគូសរំលេចខាងលើ, ខ្ញុំសូមស្នើឱ្យក្រុមប្រឹក្សាភិបាល, ថ្នាក់ដឹកនាំ និង មន្ត្រី-បុគ្គលិកគ្រប់លំដាប់ថ្នាក់របស់ធនាគារ យកចិត្តទុកដាក់លើការងារសំខាន់មួយចំនួន ដូចខាងក្រោម ៖

**ទី១**-គិតគូរដាក់ចេញនូវវិធានការ និង ផែនការសកម្មភាពលម្អិត ស្របតាមដែន-សមត្ថកិច្ចរបស់ខ្លួន ដោយសហការជិតស្និទ្ធ ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តឱ្យសម្រេចបានលទ្ធផលល្អ នូវភារកិច្ចទាំងឡាយដែលរាជរដ្ឋាភិបាល ប្រគល់ជូន;

**ទី២**-បន្តចូលរួមក្នុងដំណើរការរៀបចំ, តាមដាន និង វាយតម្លៃការអនុវត្តគោលនយោបាយ និង យុទ្ធសាស្ត្រ របស់រាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងវិស័យកសិកម្ម និង ការអភិវឌ្ឍជនបទ ដើម្បីមានកាលានុវត្តភាពបន្ថែម ក្នុងការបញ្ជ្រាបផលិតផល និង សកម្មភាពរបស់ធនាគារ ឱ្យកាន់តែច្រើន និង ទូលំទូលាយ;

**ទី៣**-ចូលរួមកៀរគរទុនវិនិយោគពីវិស័យឯកជន ឱ្យបានកាន់តែច្រើន ដើម្បីចាក់បញ្ចូលទៅក្នុងខ្សែច្រវាក់តម្លៃកសិកម្ម សំដៅរួមចំណែកអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ, ទាំងមុនពេល និង ក្រោយពេលប្រមូលផល; សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាទីផ្សារសម្រាប់កសិករ; ចូលរួមបង្កើនការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ឱ្យបានកាន់តែទូលំទូលាយ; ព្រមទាំងចូលរួមជួយជំរុញការកែច្នៃ និង ការនាំចេញនូវផលិតផលកសិកម្ម និង កសិ-ឧស្សាហកម្ម;

**ទី៤**-បន្តចូលរួមលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និង ជំរុញការពង្រីកសេវាធនាគារតាមបែបឌីជីថល ស្របតាមគោលនយោបាយអភិវឌ្ឍន៍ធុរកិច្ចឌីជីថល តាមរយៈការវិនិយោគបន្ថែម លើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង ការបង្កើតផលិតផលថ្មី;

**ទី៥**-បន្តជំរុញការធ្វើពិពិធកម្មនៃការផ្តល់ឥណទាន ដោយបែងចែកតាមតំបន់ និង វិស័យអាទិភាព តាមរយៈការបង្កើនការផ្សព្វផ្សាយ ឱ្យកាន់តែទូលំទូលាយ និង ការបង្កិតសេវា ឱ្យកាន់តែកៀកនឹងអតិថិជន;

**ទី៦**-ជំរុញការផ្តល់ហិរញ្ញប្បទានបៃតង (Green Financing) ដើម្បីជានាការ-អភិវឌ្ឍ ប្រកបដោយនិរន្តរភាព តាមរយៈការរៀបចំផ្តល់ការអនុគ្រោះបន្ថែម ឬ ផ្តល់លក្ខខណ្ឌពិសេស ជាដើម;

**ទី៧**-ចូលរួមលើកកម្ពស់ការអភិវឌ្ឍកសិករ ដែលផលិតសម្រាប់ផ្គត់ផ្គង់គ្រួសារទៅជាកសិករសហគ្រិន តាមរយៈការផ្តល់ឥណទានសម្រាប់ពង្រីក និង លើកកម្ពស់ផលិតកម្មកសិកម្ម;

**ទី៨**-បន្តកៀរគរធនធានបន្ថែម ពីប្រភពសក្តានុពលនានា, ជាពិសេស ពីប្រភពប្រាក់បញ្ញើដែលនៅមានលម្ហធំ; និង

**ទី៩**-បន្តលើកកម្ពស់ប្រសិទ្ធភាពនៃប្រតិបត្តិការរបស់ធនាគារ តាមរយៈការ-បណ្តុះបណ្តាលជំនាញបន្ថែម ព្រមទាំងការរៀបចំប្រព័ន្ធផ្តល់ការលើកទឹកចិត្តសមស្របសម្រាប់មន្ត្រី-បុគ្គលិកគ្រប់លំដាប់ថ្នាក់ ដោយគួបផ្សំជាមួយនឹងការពង្រឹងវិន័យការងារ ។

នៅចុងបញ្ចប់, ជាថ្មីម្តងទៀត, ខ្ញុំសូមអបអរសាទរយ៉ាងកក់ក្តៅ ចំពោះខួប ២៥ ឆ្នាំ នៃការបង្កើតធនាគារគោលនយោបាយដ៏មានសារៈសំខាន់នេះ និង សូមជូនពរដល់ថ្នាក់ដឹកនាំ និង មន្ត្រី-បុគ្គលិកគ្រប់ជាន់ថ្នាក់នៃធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម បានប្រកបដោយសុខភាពល្អបរិបូរណ៌, សម្រេចបានជោគជ័យធំធេងបន្ថែមទៀត ក្នុងការបំពេញភារកិច្ច បម្រើជាតិ និង មាតុភូមិ ព្រមទាំងទទួលបាននូវវិបុលភាព និង សុភមង្គល ក្នុងក្រុមគ្រួសាររៀងៗខ្លួន នៅក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាព ៕

**សូមអរគុណ**!